អង្គការថែទាំសុខភាពគ្រួសារកម្ពុជា រ៉ាក់

# ជំងឺមហារីកមាត់ស្បូន



កម្មវិធីគ្លីនិក

## សេវានៅគ្លីនិក "រ៉ាក់"

១– ពន្យារកំណើត (ថ្នាំលេប ថ្នាំចាក់ កងដាក់ដៃ កងដាក់ក្នុងស្បូន ស្រោមអនាម័យ បញ្ឈប់កំណើតរហូត (ចងដៃស្បូន និងចងបំពង់មេជីវិតបុរស

២– ពិនិត្យ និងព្យាបាលជំងឺទូទៅ (មនុស្សចាស់–កុមារ

៣– ថែទាំផ្ទៃពោះមុនសម្រាលនិងសុខភាពក្រោយសម្រាល

៤– ពិនិត្យ និងព្យាបាលជំងឺកាមរោគ (បុរស–ស្ត្រី

៥– វិភាគកោសិកាមាត់ស្បូនរកមើលជំងឺមហារីកមាត់ស្បូន

៦– ព្យាបាលដុតមាត់ស្បូនដោយឧបករណ៍ទំនើប

៧– ពិនិត្យ និងព្យាបាលសុខភាពបន្តពូជស្ត្រី និងបុរស

៨– សេវាថែទាំ និងគាំទ្រស្ត្រីត្រូវគេរំលោភ

៩– មន្ទីរពិសោធន៍វេជ្ជសាស្ត្រ

១០– ផ្តល់ប្រឹក្សា និងពិនិត្យឈាមរកមេរោគអេដស៍

១១– ផ្តល់ប្រឹក្សាអំពីសុខភាពបន្តពូជបុរស–ស្ត្រីមុនរៀបការ

១២– ព្យាបាល និងថែទាំក្រោយរលូតកូន

១៣– ព្យាបាល និងផ្តល់ប្រឹក្សាការមិនមានកូន

១៤– វះកាត់តូច

១៥– ចាក់ថ្នាំការពារតេតាណូស ថ្លើមប្រភេទវីរុសបេ និង វ៉ាក់សាំងការពារមហារីកមាត់ស្បូន

១៦– ពិនិត្យអេកូសាស្ត្រ

# ជំងឺមហារីកមាត់ស្បូន

ជំងឺមហារីកមាត់ស្បូន ជាជំងឺមហារីកលំដាប់ទី៣ ដែលគេរកឃើញញឹកញាប់ជាងគេក្នុងចំណោមជំងឺមហារីកនានានៅលើសរីរាង្គរបស់ស្ត្រី ។

នៅលើពិភពលោក ស្ត្រីប្រមាណជា១លាន ៩សែននាក់ មានជំងឺមហារីកមាត់ស្បូន ។ ជារៀងរាល់ឆ្នាំមានករណីថ្មីៗកើតមានឡើង ជាង៤៦ម៉ឺននាក់ ហើយស្ត្រីប្រហែលជា ២៣ម៉ឺន ១ពាន់នាក់ដែលបានស្លាប់ដោយសារជំងឺមហារីកមាត់ស្បូន ។ ដូច្នេះជំងឺមហារីកមាត់ស្បូនគឺជាបញ្ហាសុខភាពចម្បងរបស់ស្ត្រីទូទៅលើពិភពលោក ។

# តើជំងឺមហារីកមាត់ស្បូនបណ្តាលមកពីអ្វី ?

ភាគច្រើនលើសលុបនៃជំងឺមហារីកមាត់ស្បូនមានទំនាក់ទំនងផ្ទាល់ជាមួយនឹងការឆ្លងមេរោគ អេច ភី វី HPV ពីមុនមក។ ស្ត្រីភាគច្រើនពុំបានដឹងថាខ្លួនធ្លាប់មានឆ្លងមេរោគនេះពីមុនមកដែរឬទេ ព្រោះមេរោគនេះជារឿយៗពុំមានរោគសញ្ញា ។



ប្រយ័ត្ន

មានជំងឺមហារីកមាត់ស្បូន មួយចំនួនដែរ ដែលកើតឡើងដោយរកមូលហេតុមិនឃើញ ។

# តើស្ត្រីប្រភេទណាអាចប្រឈមមុខនឹងជំងឺមហារីកមាត់ស្បូន ?

ស្ត្រីទាំងអស់ដែលធ្លាប់ ឬកំពុងមានការរួមភេទសុទ្ធតែមានការប្រឈមមុខនឹងជំងឺមហារីកមាត់ស្បូន ។

ប្រសិនបើស្ត្រីមានលក្ខណៈណាមួយដូចរៀបរាប់ខាងក្រោម នាងនឹងមានការប្រឈមមុខរិតតែខ្ពស់ :

- ស្ត្រីដែលរួមភេទមុនអាយុ២០ឆ្នាំ
- ស្ត្រីមានដៃគូរួមភេទច្រើន
- ស្ត្រីដែលមានការប្រឈមមុខនឹងជំងឺកាមរោគ
- ស្ត្រីដែលមានម្តាយ ឬបងប្អូនស្រីធ្លាប់កើតជំងឺមហារីកមាត់ស្បូន
- ស្ត្រីដែលច្រើនព្យាបាលជំងឺដោយជាតិគ័រទីកូអ៊ីតយូរអង្វែង
- ស្ត្រីដែលធ្លាប់មានលទ្ធផល Pap smearមិនធម្មតា
- ស្ត្រីដែលមានប្រវត្តិជក់បារី

# តើជំងឺមហារីកមាត់ស្បូនមានរោគសញ្ញា ដូចម្តេចខ្លះ ?

ជាទូទៅនៅតំណាក់កាលដំបូង ជំងឺមហារីកមាត់ស្បូន គ្មាន រោគសញ្ញាអ្វីទាំងអស់ តែក្រោយមកអាចមានចេញ រោគសញ្ញាដូចជា ធ្លាក់ទឹកសឿងៗមិនធម្មតាពីទ្វារមាស មានធ្លាក់ឈាមក្រោយពេលរួមភេទ មានធ្លាក់ឈាម ដោយឯកឯងនៅចន្លោះរដូវ និងមានការឈឺចាប់នៅផ្នែក ក្រោមពោះ ។



ទោះជាគ្មានរោគសញ្ញាអ្វីក៏ដោយ នៅពេលដល់ អាយុ៣៥ ទៅ៤៥ឆ្នាំ ស្ត្រីត្រូវតែទៅពិនិត្យរក កោសិកាមហារីកមាត់ស្បូនឲ្យបានយ៉ាងតិច១ឆ្នាំម្តង។

# តើត្រូវពិនិត្យអ្វីខ្លះដើម្បីដឹងថាស្ត្រីមានជំងឺមហារីកមាត់ស្បូន ?

ជម្រើសដែលប្រសើរបំផុតនោះគឺ ត្រូវទៅជួបជាមួយគ្រូពេទ្យ រោគស្ត្រី ដើម្បីឲ្យគាត់ពិនិត្យមាត់ស្បូនរកការប្រែប្រួលនៃកោសិកាមាត់ស្បូន ។

មានវិធីច្រើនក្នុងការស្រាវជ្រាវរកការប្រែប្រួលនៃកោសិកាមាត់ស្បូន តែវិធីដែលងាយរកបាន និងរហ័សទាន់ចិត្ត គឺការពិនិត្យមើលមាត់ស្បូនដោយតេស្តម្យ៉ាងឈ្មោះថា វី អាយ អេ (VIA ។



ស្ត្រីមានសិទ្ធិក្នុងការសម្រេចចិត្តជ្រើសរើសវិធីស្រាវជ្រាវរកការប្រែប្រួលកោសិកាមាត់ស្បូនដោយសេរីនិងគ្មានការបង្ខិតបង្ខំ។

# តើការពិនិត្យមានភាពឈឺចាប់ឬទេ ? ហើយផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់ស្ត្រី ?

ជាទូទៅការពិនិត្យមាត់ស្បូនមិនមានការឈឺចាប់ទេ ។ ស្ត្រីខ្លះ មានអារម្មណ៍អួលៗឬផ្សាបន្តិចបន្តួចក្នុងពេលកំពុងពិនិត្យ ប៉ុន្តែ នឹងបាត់ភ្លាមដោយឯកឯងនៅពេលពិនិត្យរួច ។

ការពិនិត្យផ្ដល់ប្រយោជន៍ឲ្យស្ត្រី មិនត្រឹមតែអាចរកឃើញរាល់ការប្រែប្រួលនានានៃកោសិកាមាត់ស្បូនដែលអាចឈានទៅរកមហារីកមាត់ស្បូនប៉ុណ្ណោះទេ ថែមទាំងផ្ដល់ឱកាសឲ្យស្ត្រីអាចទទួលបានការធ្វើរោគវិនិច្ឆ័យ និងព្យាបាលគ្រប់គ្រាន់នៃជំងឺរោគស្ត្រីមួយចំនួនផ្សេងទៀត រួមទាំងការករោគទៅតាមផ្លូវបន្តពូជថែមទៀតផង ។

ស្ត្រីគួរតមការលូកលាងទៅក្នុងទ្វារមាស ឬ ប្រើសំឡី ឬ ថ្នាំញាត់ចូលក្នុងទ្វារមាស ២ថ្ងៃមុនពេលពិនិត្យ ។

# តើត្រូវព្យាបាលដែរឬទេនៅពេលដឹងថា កោសិកាមាត់ស្បូនមានការប្រែប្រួល ?

ជំងឺមហារីមាត់ស្បូនអាចព្យាបាលជាបានតែនៅក្នុងដំណាក់កាលដំបូង គឺនៅពេលដែលការពិនិត្យមាត់ស្បូនរកឃើញថាមានការប្រែប្រួលកោសិកាមិនធម្មតា ដែលជាសញ្ញាអាចបញ្ជាក់បានថាវាអាចវិវត្តទៅជាមហារីកនៅថ្ងៃក្រោយ ។ ក្នុងករណីនេះ គ្រូពេទ្យរោគស្ត្រីគឺជាមនុស្សប្រសើរបំផុតសម្រាប់អ្នកក្នុងការពិភាក្សាអំពីការព្យាបាល ។



នៅគ្លីនិក រ៉ាក់ មាន ឧបករណ៍ដុតត្រជាក់ ដែលជាវិធីព្យាបាលលើករណីនៃការប្រែប្រួលកោសិកាមាត់ស្បូនយ៉ាងមានប្រសិទ្ធិភាព ។

# តើធ្វើដូចម្តេចដើម្បីបង្ការជំងឺមហារីកមាត់ស្បូន ?

- ជំហានដំបូងត្រូវប្រើស្រោមអនាម័យពេលរួមភេទ បើអ្នកមានដៃគូរួមភេទច្រើន ឬដៃគូមិនជាប់លាប់ ។
- ចំពោះស្ត្រីដែលមានឬធ្លាប់មានការរួមភេទ ការពិនិត្យ ស្រាវជ្រាវរកតំបន់ប្រែប្រួលមិនធម្មតានៃមាត់ស្បូនគឺជាវិធីប្រសើរបំផុតដែលអាចផ្តល់លទ្ធភាពឲ្យស្ត្រីអាចព្យាបាលទាន់ពេលវេលា និងការពារមិនឲ្យមានការវិវត្តន៍ទៅរកមហារីកមាត់ស្បូនបាន ។
- តេស្តមួយចំនួនទៀត និងវ៉ាក់សាំងការពារការឆ្លងមេរោគ អេច ភី វី HPV ក៏អាចការពារបានដែរតែមានតម្លៃថ្លៃ។

**ចំណាំ**

ស្ត្រីគួរតែទៅពិនិត្យស្បូនដើម្បីរកកោសិកាមហារីកមាត់ស្បូនឲ្យបាន១ឆ្នាំម្តង ។

# សិទ្ធិរបស់អតិថិជនដែលមកទទួលសេវា នៅគ្លីនិក “រ៉ាក់” មានដូចខាងក្រោម :

១- *សិទ្ធិក្នុងការទទួលយកព័ត៌មាន :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលយកព័ត៌មានស្តីអំពីផលប្រយោជន៍នៃការពន្យារកំណើត ទីកន្លែងផ្តល់សេវាពន្យារកំណើត និងសេវាថែទាំសុខភាពផ្លូវភេទ ។

២- *សិទ្ធិក្នុងការទទួលសេវា :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាពន្យារកំណើតដោយមិនគិតអំពីស្ថានភាពសង្គម សេដ្ឋកិច្ច សាសនា និន្នាការ នយោបាយ ជនជាតិ ពណ៌សម្បុរ ស្ថានភាពអាពាហ៍ពិពាហ៍ ឬទីកន្លែងស្នាក់នៅឡើយ ។

៣- *សិទ្ធិក្នុងការជ្រើសរើស :* អតិថិជនទាំងអស់មានសិទ្ធិសម្រេចចិត្តក្នុងការជ្រើសរើសប្រើប្រាស់ ឬមិនប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយដោយសេរី ។

៤- *សិទ្ធិមានសុវត្ថិភាព :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលបាននូវសុវត្ថិភាព សុខភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្តក្នុងការប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយ ។

៥- *សិទ្ធិឯកជន :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការពិភាក្សាតម្រូវការ ការព្រួយបារម្ភ ឬការពិនិត្យរាងកាយរបស់ពួកគេ នៅក្នុងទីកន្លែងណាដែលគេមានអារម្មណ៍កក់ក្តៅ ។

៦- *សិទ្ធិរក្សាការសម្ងាត់ :* អតិថិជនទាំងអស់គួរតែត្រូវបានធានាថារាល់ព័ត៌មានទាំងឡាយដែលគេបានប្រាប់ ឬសេវាទាំងឡាយដែលគេបានទទួលនឹងមិនត្រូវបន្តទៅអ្នកទីពទេ លើកលែងតែមាន ការយល់ព្រមពីសាម៉ីខ្លួន ។

៧- *សិទ្ធិរក្សាភាពថ្លៃថ្នូរ និងកិត្តិយស :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលរាក់ទាក់ដោយភាពគួរសម ការយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន និងការគោរពដោយភាពថ្លៃថ្នូរ ដោយមិនប្រកាន់នូវចំណេះដឹង ស្ថានភាពសង្គម ឬឋានន្តរសក្តិឡើយ ។

៨- *សិទ្ធិមានផាសុកភាព :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាកម្មដែលមានលក្ខណៈផាសុកភាពដោយអារម្មណ៍ពេញចិត្តពេញថ្លើម ។

៩- *សិទ្ធិក្នុងការបន្ត :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាកម្ម និងមធ្យោបាយពន្យារកំណើតបានយូរទៅតាមសេចក្តីត្រូវការរបស់ពួកគេ ។

១០- *សិទ្ធិក្នុងការបញ្ចេញមតិយោបល់ :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការបញ្ចេញយោបល់ និងទស្សនៈ អំពីការផ្តល់សេវាកម្មដែលពួកគេបានទទួល ។

# RITAC អាសយដ្ឋានគ្លីនិក "រ៉ាក់"

## រាជធានីភ្នំពេញ

**គ្លីនិកភ្នំពេញ១** : ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ២៦ ផ្លូវលេខ១៥០ ស.វាលវង់
ខណ្ឌ៧មករា ទូរស័ព្ទ : ០២៣-៨៨១ ៦២១

**គ្លីនិកភ្នំពេញ២** : ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ៣៨-៤០ ផ្លូវលេខ៤៣២ ស.ទួលទំពូង១
ខណ្ឌចំការមន ទូរស័ព្ទ : ០២៣-២១៨ ៥០៤

**គ្លីនិកស្ទឹងមានជ័យ** : ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ ១៩. ២០. ២១ ភូមិត្រពាំងឈ្វើង
ស.ចោមចៅ ខណ្ឌដង្កោ
ទូរស័ព្ទ : ០២៣-៩៨៥ ៧៧៣

**គ្លីនិកចាក់អង្រែក្រោម** :( មានសេវាពិនិត្យ MSM )
ផ្ទះលេខ ១៦០៧ ភូមិទួលរកា
ស.ចាក់អង្រែក្រោម ខណ្ឌមានជ័យ
ទូរស័ព្ទ : ០២៤-៩៨៥ ០៧៩

**គ្លីនិកទួលសង្កែ / មណ្ឌលយុវវ័យ**:( មានសេវាពិនិត្យMSM)
ផ្ទះលេខ ១៦២៤ ផ្លូវជាតិលេខ៥ ភូមិឃ្លាំងសាំង
ក្រុម៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ
ទូរស័ព្ទ :០២៣-៩៩០ ៧៧៣

**គ្លីនិកទឹកថ្លា** : ( មានសេវាពិនិត្យ MSM )
ផ្ទះលេខG35-G37 ផ្លូវហ្វូដឌី
សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ
ទូរស័ព្ទ : ០២៣-៨៨៣ ០២៦

**គ្លីនិកទំនប់ថ្មី** : ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ៣A+៤A ផ្លូវមុន្នីរ៉េត
ភូមិដំណាក់ធំ១ សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ ទូរស័ព្ទ : ០២៣-៩៩៥ ៤៧៦

## ខេត្តបាត់ដំបង

**គ្លីនិក** :( មានសេវាពិនិត្យ MSM )
ផ្ទះលេខ១៩៤,៤៤៩ ភូមិព្រែកមហាទេព
ឃុំស្វាយប៉ោ ស្រុកបាត់ដំបង
ទូរស័ព្ទ : ០៥៣-៩៥២ ៦១០

## ខេត្តព្រះសីហនុ

**គ្លីនិក / មណ្ឌលយុវវ័យ**:( មានសេវាពិនិត្យ MSM )
ផ្ទះលេខ៥៥៥ ផ្លូវឯករាជ្យ មណ្ឌល៤ សង្កាត់៤
ខណ្ឌមិត្តភាព ទូរស័ព្ទ : ០៣៤-៩៣៣ ៩៤២

## ខេត្តកំពង់ចាម

**គ្លីនិក / មណ្ឌលយុវវ័យ**:( មានសេវាពិនិត្យ MSM )
ផ្ទះលេខ១០ ផ្លូវត្រសក់ផ្អែម ភូមិ១៥ ឃុំកំពង់ចាម
ស្រុកកំពង់ចាម ទូរស័ព្ទ : ០៤២-៩៤១ ៥០២

**គ្លីនិកសួង** : ( មានសេវាពិនិត្យ MSM )
ភូមិសួងលិច ឃុំសួង ស្រុកត្បូងឃ្មុំ
ទូរស័ព្ទ : ០១៦-៣០៦ ៥១១

## ខេត្តតាកែវ

**គ្លីនិក** : ផ្ទះលេខ៥ ផ្លូវលេខ៨ ភូមិឡូរី
សង្កាត់រការក្នុង ក្រុងដូនកែវ
ទូរស័ព្ទ : ០៣២-៩៣១ ៣៦១

## ខេត្តសៀមរាប

**គ្លីនិក / មណ្ឌលយុវវ័យ** :( មានសេវាពិនិត្យ MSM )
ភូមិត្រពាំងសេះ ឃុំគោកចក
ទូរស័ព្ទ : ០៦៣-៩៦៤ ៩៦០

## ខេត្តកំពង់ស្ពឺ

**គ្លីនិក / មណ្ឌលយុវវ័យ** : ( មានសេវាពិនិត្យ MSM )
ភូមិស្មោរទី១ សង្កាត់រកាធំ ក្រុងច្បារមន
ខេត្តកំពង់ស្ពឺ ទូរស័ព្ទ :០២៥-៩៨៧ ១៤៥

## ខេត្តស្វាយរៀង

**គ្លីនិក** : ៥០ ភូមិបាវិតកណ្តាល សង្កាត់បាវិត
ក្រុងបាវិត ទូរស័ព្ទ : ០៤៤-៩៤៦ ០៦៦

## ខេត្តកំពត

**គ្លីនិក** : ផ្ទះលេខ៥១ ផ្លូវជាតិលេខ៣៣
ភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត
ទូរស័ព្ទ : ០៣៣ ៩៣២ ៧៦៨

សៀវភៅនេះផលិតតាមបច្ចេកទេស និងគំនិតរបស់បុគ្គលិក
អង្គការ " រ៉ាក់ " ក្រោមការឧបត្ថម្ភថវិការបស់
ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ USAID
ក្រោមគម្រោងរួមគ្នាដើម្បីសុខភាពល្អ

USAID ជំនួយពីពលរដ្ឋអាមេរិក រួមគ្នាដើម្បីសុខភាពល្អ RHAC

<u>កំណត់សម្គាល់:</u> តួអង្គនៅក្នុងសៀវភៅ គ្រាន់តែជាការសម្ដែងប៉ុណ្ណោះ

បោះពុម្ពលើកទី.... ចំនួន ............... ក្បាល ឆ្នាំ២០១២

IEC,2012